# ព្រះរាជក្រឹត្យ

នស/រកត/១១០៣/៣៣២

## ស្តីពី

## រូបសញ្ញាសុខាភិបាល សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រី
## នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម

**យើង**

**ព្រះបាទសម្តេចព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៤ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំពី សម្តេចនាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៣

# ត្រាស់បង្គាប់

## ជំពូក ទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើតរូបសញ្ញាសុខាភិបាល សញ្ញាស័ក្តិ និង ឯកសណ្ឋានសំរាប់សំគាល់មន្ត្រីរាជការ ក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម ដែលបំរើការងារនៅក្រោមឱវាទ ក្រសួងសុខាភិបាល និង នៅតាមក្រសួងស្ថាប័ននានា នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២.-**

សញ្ញាស័ក្តិ និងឯកសណ្ឋាននេះ សំរាប់ប្រើប្រាស់នៅពេលចូលរួមពិធីបុណ្យប្រពៃណីជាតិ ពិធីបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗ ។

## ជំពូក ទី ២

## រូបសញ្ញាសុខាភិបាល

**មាត្រា៣.-**

រូបសញ្ញាសុខាភិបាល ត្រូវបានកំណត់ដូចតទៅ :

- មានរាងពងក្រពើ លំអដោយពណ៌មាស ក្រហម ខៀវ ស និងបៃតង
- ទទឹងប្រវែង ៤ ភាគ ៥ នៃ បណ្តោយ
- នៅខាងក្រោមចំកណ្តាល មានក្បាច់ដកចន្ទន៍ និងមានផ្ទាំងសញ្ញាពណ៌ទង់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា ដែលមានចារឹកអក្សរថា សុខាភិបាលនិងមានស្លឹករុក្ខជាតិពីរជុំវិញរាងជាស្នែងក្របីពណ៌បៃតង
- នៅចំកណ្តាលមានរូបម្ពុលមួយ ដែលពត់ពេនព័ទ្ធជុំវិញដោយពស់មួយក្បាល
- នៅចំខាងលើម្ពុលមានម្កុដរាជ នៅលើម្កុដរាជមានការស្មី១៥ កាំ ។

រូបសញ្ញាសុខាភិបាលនេះ សំរាប់ដាក់នៅលើស័ក្តិស្មា ស័ក្តិចុងកអាវ និង ដាក់នៅលើស័ក្តិខ្ទាស់លើអាវបុរស ឬលើក្រមាពានារបស់នារី នៃមន្ត្រីក្របខ័ណ្ឌ មន្ត្រីសុខាភិបាលជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម ។

រូបសញ្ញាសុខាភិបាលនេះ មានរូបភាពដូចក្នុងឧបសម្ព័ន្ធទី ១ ។

## ជំពូក ទី ៣
## សញ្ញាស័ក្តិ

**មាត្រា៤.-**

សញ្ញាស័ក្តិមន្ត្រីក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ និងមន្ត្រីក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម ត្រូវកំណត់ដូចតទៅ :

### ក-ក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ :

### ១.អំពីស័ក្តិស្មា :

ស័ក្តិស្មាមាន ផ្ទៃកម្ចីពណ៌ឈាមជ្រូកចាស់រចនាតុបតែងដោយក្បាច់ភ្ញីល្វីប្រភេទស្លឹកព្នៅពីរមែកពណ៌មាស ដាក់ខ្នងគ្នាហើយនៅពីលើក្បាច់ទាំងពីរនេះ មានរូបសញ្ញាសុខាភិបាលពណ៌មាស និង នៅពីលើខាងរូបសញ្ញាសុខាភិបាល មានឡេវរូបព្រះសង្ហារ ពណ៌មាសមួយ ។ បន្ទាប់មកមានក្បាច់ផ្កាដួងមួយខ្សែពណ៌មាសព័ទ្ធជុំវិញក្នុងឋាន ។ ផ្ទៃខាងក្រៅនៃក្បាច់ផ្កាដួងនេះមានខ្សែពួរវេញព័ទ្ធជុំវិញពណ៌មាស បីខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស ពីរខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ និង មួយខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលជាន់ខ្ពស់ ។

ខ្នាតស័ក្តិស្មាត្រូវបានកំណត់ដូចខាងក្រោម :

- បាតក្រោម ប្រវែង ៦ សង្ទីម៉ែត្រ
- ទទឹងមុខកាត់ផ្នែកខាងលើ ប្រវែង ៤,៤០ សង្ទីម៉ែត្រ មានរាងកោងជាមុំទាល
- បណ្តោយពីលើដល់បាតក្រោម ប្រវែង ១៣ សង្ទីម៉ែត្រ ។

### ២.អំពីស័ក្តិចុងកអាវខាងសងខាង

ស័ក្តិចុងកអាវមានផ្ទៃកម្ចីពណ៌ឈាមជ្រូកចាស់រចនាតុបតែងដោយក្បាច់ភ្ញីល្វីប្រភេទស្លឹកព្នៅពីរមែកពណ៌មាស ដាក់ខ្នងគ្នាហើយមានរូបសញ្ញាសុខាភិបាលពណ៌មាសនៅពីខាងមុខ ។ បន្ទាប់មកមានក្បាច់ផ្កាដួងពណ៌មាសមួយខ្សែនិងមានខ្សែពួរវេញពណ៌មាសនៅផ្នែកខាងលើភ្ជាប់ជាមួយចំហៀងខាងមុខ បីខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស ពីរខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ និង មួយខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលជាន់ខ្ពស់ ។

ខ្នាតស័ក្តិចុងកអាវត្រូវបានកំណត់ដូចខាងក្រោម :

- មានរាងជាប្រលេឡូក្រាម
- បណ្តោយ ប្រវែង ៩ សង្ទីម៉ែត្រ
- ទទឹង ប្រវែង ៣,៨ សង្ទីម៉ែត្រ ។

### ៣.អំពីស័ក្តិចុងដៃអាវខាងសងខាង

ស័ក្តិចុងដៃអាវមានផ្ទៃកម្ចីពណ៌ឈាមជ្រូកចាស់រចនាតុបតែង ដោយក្បាច់ភ្ញីល្វីប្រភេទស្លឹកព្នៅឯមែកពណ៌មាស និងមានក្បាច់ផ្កាដួងពណ៌មាសមួយខ្សែនៅខាងលើ និងជាយផ្នែកចំហៀងសងខាង ។ ផ្ទៃខាងក្រៅនៃក្បាច់ផ្កាដួងនេះ មានខ្សែពួរវេញពណ៌មាសនៅផ្នែកខាងលើ និង ផ្នែកចំហៀងទាំងសងខាង បីខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស ពីរខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ និង មួយខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិ មន្ត្រី

សុខាភិបាលជាន់ខ្ពស់ ។ នៅបាតក្រោមបង្អស់នៃសញ្ញាស័ក្តិចុងដៃអាវ មានខ្សែព្ទរវេញពណ៌មាសមួយខ្សែ ។

ខ្នាតនៃស័ក្តិចុងដៃអាវទាំងសងខាង ត្រូវបានកំណត់ដូចខាងក្រោម :

- មានរាងបួនជ្រុងទ្រវែង
- បណ្តោយ ប្រវែង ៣២ សង្ទីម៉ែត្រ
- ទទឹង ប្រវែង ៩ សង្ទីម៉ែត្រ ។

រូបសញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវទាំងសងខាង សំរាប់មន្ត្រី :

- ឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស មានដូចក្នុងឧបសម្ព័ន្ធទី ២
- ឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ មានដូចក្នុងឧបសម្ព័ន្ធទី ៣
- ឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ មានដូចក្នុងឧបសម្ព័ន្ធទី ៤ នៃព្រះរាជក្រឹត្យនេះ ។

ដោយឡែកស័ក្តិស្មា ស័ក្តិចុងកអាវ និងស័ក្តិចុងដៃអាវទាំងសងខាងសំរាប់នារី មានទំហំដូចខាងក្រោមនេះ :

- ចំពោះស័ក្តិស្មា អាចមានទំហំ ៨០% ៨៥ %៩០% នៃទំហំស័ក្តិស្មារបស់បុរស អាស្រ័យលើមាឌរបស់នារី
- ស័ក្តិចុងកអាវ មានទំហំទទឹង ៣ សង្ទីម៉ែត្រ ទៅ ៣,៥ សង្ទីម៉ែត្រ អាស្រ័យលើកំពស់ករបស់នារី
- ចំពោះស័ក្តិចុងដៃអាវ អាចមានទំហំទទឹងស្មើនឹង ៧០% ទៅ ៧៥% នៃទំហំទទឹងស័ក្តិចុងដៃអាវ បុរស អាស្រ័យ លើមាឌរបស់នារី ។

## ៤_អំពីស័ក្តិខ្ទាស់លើអាវសំរាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់

ស័ក្តិខ្ទាស់លើអាវសំរាប់ មន្ត្រីក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ មានរាងសាជី ដែលបាតក្រោមមានរាងពងក្រពើ និង កំពូលរាងជ្រលម កំពស់ ៦ សង្ទីម៉ែត្រ ទទឹង ៥ សង្ទីម៉ែត្រ ។ ផ្នែកខាងក្នុងមានរូបសញ្ញាសុខាភិបាលពណ៌មាស បន្ទាប់មកមាន ក្បាច់ផ្កាដូងពណ៌មាសមួយព័ទ្ធអមផង។ ផ្នែកខាងក្រៅមានខ្សែព្ទរវេញព័ទ្ធអមពណ៌មាស បីខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស ពីរខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ និង មួយខ្សែសំរាប់ សំគាល់ឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ ។

ស័ក្តិខ្ទាស់លើអាវនេះ សំរាប់ខ្ទាស់លើអាវនៅពេលបំពេញការងារ ។ ស័ក្តិនេះក៏សំរាប់ខ្ទាស់លើក្រមាពានា នារីក្នុង ឯកសណ្ឋានប្រពៃណីដែរ ។

រូបគំនូរស័ក្តិខ្ទាស់លើអាវ និងលើក្រមាពានាសំរាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ មានដូចក្នុងឧបសម្ព័ន្ធទី ៥ នៃព្រះរាជក្រឹត្យនេះ ។

## ខ_ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម

សញ្ញាស័ក្តិសំរាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម មានសណ្ឋានរូបភាព និងមានការកំណត់បែងចែកទៅតាម ប្រភេទ ឋានន្តរស័ក្តិ ដូចសញ្ញាស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដែរ ប៉ុន្តែខុសគ្នាត្រង់សញ្ញាស័ក្តិសំរាប់ក្របខ័ណ្ឌមន្ត្រីសុខាភិបាល មធ្យមមានពណ៌ប្រាក់ ។

រូបសញ្ញាស័ក្តិស្នា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវសំរាប់ :

- ឋានន្តរស័ក្តិមន្ត្រីសុខាភិបាលមធ្យមដើមខ្សែពិសេស មានដូចក្នុងឧបសម្ព័ន្ធទី ៦
- ឋានន្តរស័ក្តិមន្ត្រីសុខាភិបាលមធ្យមដើមខ្សែ មានដូចក្នុងឧបសម្ព័ន្ធទី ៧
- និងឋានន្តរស័ក្តិមន្ត្រីសុខាភិបាលមធ្យម មានដូចក្នុងឧបសម្ព័ន្ធទី ៨ នៃព្រះរាជក្រឹត្យនេះ ។

## ជំពូក ទី ៤
## ប្រភេទឯកសណ្ឋាន និង ការប្រើប្រាស់

**មាត្រា៥.-**

ប្រភេទឯកសណ្ឋានសំរាប់ មន្ត្រីក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម ត្រូវបានកំណត់ដូចខាងក្រោម :

**ក.-ឯកសណ្ឋានផ្លូវការ**

**១.-ចំពោះបុរស**

- អាវកុដពណ៌ស កត្រង់ ដៃវែង កាត់រាងអាវធំ មានបន្ទះលើស្មាសំរាប់ដាក់ស័ក្តិ និងគ្មានផែកខ្នង ។ អាវនេះមាន ហោប៉ៅចំនួនបួន គឺហោប៉ៅខាងលើពីរដេរបង្កប់ មានគំរបរាងបួនជ្រុងទ្រវែងមានគែមរាងមូល ហោប៉ៅខាងក្រោមពីរដេរបង្កប់ មានគំរបរាងបួនជ្រុងទ្រវែងមានគែមរាងមូល ហើយនៅលើគំរបហោប៉ៅទាំងបួននោះ មានឡេវរូបព្រះសង្ហារពណ៌មាស ឬ ពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌ ។ អាវកុដពណ៌សនេះ មានឡេវរូបព្រះសង្ហារចំនួន៧ ពណ៌មាស ឬ ពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌ ។
- ខោជើងវែងមានពណ៌ស ស្បែកជើងឃ្មុបពណ៌ខ្មៅចងខ្សែ និង ស្រោមជើងពណ៌ខ្មៅ ។

**២.-ចំពោះស្ត្រី**

- អាវជីបរាងពណ៌សដោយប្រើសាច់ក្រណាត់ដូចឈុតអាវ របស់បុរស កតាំង ដៃវែង ត្រឹមភ្នែកគោលដៃ គ្មាន ផែកខ្នង ។ បិទឡេវមុខ ដាក់ឡេវរូបព្រះសង្ហារចំនួន៥ ពណ៌មាស ឬពណ៌ប្រាក់ ទៅតាមក្របខ័ណ្ឌ ។ ចុងកអាវមានស័ក្តិ លើស្មាមានបន្ទះសំរាប់ដាក់ស័ក្តិ គ្មានហោប៉ៅ ។
- សំពត់សំឡូយពណ៌ស មានសំរុងលើភ្នែកគោល នៃស្មងជើង ប្រវែងពី ១០ ទៅ ១៥ សង្ទីម៉ែត្រ អនុលោមទៅតាមមាឌ និង កំពស់របស់នារី ។
- ស្បែកជើងឃ្មុបមុខ ឃ្មុបក្រោយ មានកែង ពណ៌សសំរាប់ពេលព្រឹក ពណ៌ខ្មៅសំរាប់ពេលល្ងាច ។

រូបគំនូរឯកសណ្ឋានផ្លូវការសំរាប់បុរស និងស្ត្រី នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៩ និងមន្ត្រីក្របខ័ណ្ឌ មន្ត្រីសុខាភិបាលមធ្យម មានគំរូដូចក្នុងឧបសម្ព័ន្ធទី ១០ នៃព្រះរាជក្រឹត្យនេះ ។

## ខ_ឯកសណ្ឋានប្រពៃណីជាតិ

### ១_ចំពោះបុរស

- អាវកុដពណ៌ស កគ្រង ដៃវែងកាត់រាងអាវធំ មានបន្ទះលើស្មាសំរាប់ដាក់ស័ក្តិ និងគ្មានផែកខ្នង ។ អាវនេះមាន ហោប៉ៅចំនួនបួន គឺហោប៉ៅខាងលើពីរដេរបង្កប់ មានគំរបរាងបួនជ្រុងទ្រវែងមានតែមរាងមូល ហោប៉ៅខាងក្រោមពីរដេរបង្កប់ មានគំរបរាងបួនជ្រុងទ្រវែងមានតែមរាងមូល ហើយនៅលើគំរបហោប៉ៅទាំងបួននោះ មានឡេវរូបព្រះសង្ហារពណ៌មាស ឬ ពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌ ។ អាវកុដពណ៌សនេះ មានឡេវរូបព្រះសង្ហារចំនួន៧ ពណ៌មាស ឬពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌ ។
- សំពត់ផាមួងចងក្បិន ពណ៌តាមថ្ងៃ
- ស្បែកជើងឃ្លុបពណ៌ខ្មៅ កខ្លី មានចងខ្សែ ស្រោមជើងពណ៌ខ្មៅដល់ក្បាលជង្គង់ ។

### ២_ចំពោះស្ត្រី

- អាវជីបរាងពណ៌ស មានកមូល ដៃវែង រួតខ្លួនបន្តិចនៅចុងដៃអាវមានស័ក្តិ និងមានឡេវបញ្ចោត៣ រូបព្រះសង្ហារពណ៌មាស ឬ ពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌ ។
- សំពត់ផាមួងចងក្បិន ពណ៌តាមថ្ងៃ
- ពានាក្រមាតាមពណ៌សំពត់ ឬពានាក្រមាពណ៌ស៊ីន្ទួន តាមពិធីការកំណត់
- នៅលើក្រមាពានាផ្នែកខាងឆ្វេងនៃដើមទ្រូង មានស័ក្តិខ្ចាស់សំគាល់ឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ ឬ មធ្យម.
- ស្បែកជើងឃ្លុបមុខ ឃ្លុបក្រោយ មានកែង ពណ៌សសំរាប់ពេលព្រឹក ពណ៌ខ្មៅសំរាប់ពេលល្ងាច
- កាបូបយួរដៃ ពណ៌ស ឬ ពណ៌ខ្មៅ ( មិនអោយស្ពាយទេ ) ស្របតាមការប្រើស្បែកជើង ពណ៌ស ឬ ពណ៌ខ្មៅ ។

រូបគំនូរឯកសណ្ឋានប្រពៃណីជាតិសំរាប់បុរស និងស្ត្រី នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ មានគំរូដូចក្នុងឧបសម្ព័ន្ធទី ១១ និងមន្ត្រីក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម មានគំរូដូចក្នុងឧបសម្ព័ន្ធទី ១២ នៃព្រះរាជក្រឹត្យនេះ ។

## មាត្រា ៦._

ការប្រើប្រាស់ឯកសណ្ឋានសំរាប់មន្ត្រីសុខាភិបាលជាន់ខ្ពស់ និងមន្ត្រីសុខាភិបាលមធ្យម ត្រូវបានកំណត់ដូចខាងក្រោមៈ

- ឯកសណ្ឋានផ្លូវការសំរាប់ប្រើប្រាស់ ក្នុងឱកាសទិវាបុណ្យប្រពៃណីជាតិ និងពិធីការផ្សេងៗ ។
- ចំពោះឯកសណ្ឋានប្រពៃណីជាតិសំរាប់ប្រើប្រាស់ក្នុងទិវាបុណ្យប្រពៃណីជាតិ និងសាសនាដែលប្រារព្ធធ្វើឡើងនៅក្នុងព្រះបរមរាជវាំង ក្នុងវត្តអារាម ឬទីកន្លែងផ្សេង ៗ ត្រូវបានកំណត់អោយប្រើឯកសណ្ឋាននេះ តែមន្ត្រីក្របខ័ណ្ឌ មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស ។

## ជំពូក ទី ៥

## របបកំណត់ឯកសណ្ឋាន និង សញ្ញាស័ក្តិ

**មាត្រា ៧.-**

ត្រូវបានផ្តល់ជូនដល់មន្ត្រីម្នាក់ៗ នូវឯកសណ្ឋានផ្លូវការ មួយសំរាប់ និងឯកសណ្ឋានប្រពៃណីជាតិ មួយសំរាប់ ព្រមទាំងសញ្ញាស័ក្តិ និងសំភារៈផ្សេងៗ ទៀត ដូចបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ សំរាប់ប្រើប្រាស់រយៈពេលបីឆ្នាំម្តង ។

## ជំពូក ទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ៨.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩.-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៣

**ព្រះហស្តលេខា និង ព្រះរាជលញ្ជករ**

**នរោត្តម សីហនុ**

៣រ/ស.០៣.១១.៣៤៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
នៃព្រះរាជាណាចក្រកម្ពុជា សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ: ២៧៦ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible] តាន់

ឧបសម្ព័ន្ធទី ១ នៃព្រះរាជក្រឹត្យលេខ នស/រកត/១១០៣/៣៣៤
ចុះថ្ងៃទី២៤ខែវិច្ឆិកាឆ្នាំ២០០៣ស្ដីពីរូបសញ្ញាសុខាភិបាល សញ្ញាស័ក្តិ និងឯកសណ្ឋាន
មន្ត្រីនៃ ក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ និង ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម

# រូបសញ្ញា សុខាភិបាល

ឧបសម្ព័ន្ធទី ២ នៃព្រះរាជក្រឹត្យលេខ នស/រកត/១១០៣/៣៣៦
ចុះថ្ងៃទី២៤ខែវិច្ឆិកាឆ្នាំ២០០៣ស្តីពីរូបសញ្ញាសុខាភិបាល សញ្ញាស័ក្តិ និងឯកសណ្ឋាន
មន្ត្រីនៃ ក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ និង ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម

# សញ្ញាស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស (ពណ៌មាស)



ស័ក្តិកអាវ



ស័ក្តិប៉ានស្មា



ស័ក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/១១០៣/៣៣៤
ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៣ស្តីពីរូបសញ្ញាសុខាភិបាល សញ្ញាស័ក្តិ និងឯកសណ្ឋាន
មន្ត្រីនៃ ក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ និង ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម

## សញ្ញាស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ (ពណ៌មាស)



ស័ក្តិករអាវ



ស័ក្តិប៉ាន់ស្មា



ស័ក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០៣/៣៣២
ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីរូបសញ្ញាសុខាភិបាល សញ្ញាស័ក្តិ និងឯកសណ្ឋាន
មន្ត្រីនៃ ក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ និង ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម

# សញ្ញាស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ (ពណ៌មាស)



ស័ក្តិករអាវ



ស័ក្តិបានស្មា



ស័ក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/១១០៣/៣៧៤
ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីរូបសញ្ញាសុខាភិបាល សញ្ញាស័ក្តិ និងឯកសណ្ឋាន
មន្ត្រីនៃ ក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ និង ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម

# ស័ក្តិខ្ទាស់លើអាវសំរាប់មន្ត្រី
# នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់



សំរាប់ឋានន្តរស័ក្តិ
មន្ត្រីជាន់ខ្ពស់ដើមខ្សែពិសេស



សំរាប់ឋានន្តរស័ក្តិ
មន្ត្រីជាន់ខ្ពស់ដើមខ្សែ



សំរាប់ឋានន្តរស័ក្តិ
មន្ត្រីជាន់ខ្ពស់

ឧបសម្ព័ន្ធទី ៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១១០៣/៣៣៤
ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីរូបសញ្ញាសុខាភិបាល សញ្ញាស័ក្តិ និងឯកសណ្ឋាន
មន្ត្រីនៃ ក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ និង ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម

# សញ្ញាស័ក្តិមន្ត្រីសុខាភិបាលមធ្យមដើមខ្សែពិសេស (ពណ៌ទឹកប្រាក់)



ស័ក្តិកអាវ



ស័ក្តិប៉ាទស្មា



ស័ក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ៧ នៃព្រះរាជក្រឹត្យលេខ នស/រកត/១១០៣/៣៣៤
ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីរូបសញ្ញាសុខាភិបាល សញ្ញាស័ក្តិ និងឯកសណ្ឋាន
មន្ត្រីនៃ ក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ និង ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម

# សញ្ញាស័ក្តិមន្ត្រីសុខាភិបាលមធ្យមដើមខ្សែ (ពណ៌ទឹកប្រាក់)



ស័ក្តិកអាវ



ស័ក្តិប៉ានស្មា



ស័ក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ៨ នៃព្រះរាជក្រឹត្យលេខ នស/រកត/១១០៣/៣៣២
ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីរូបសញ្ញាសុខាភិបាល សញ្ញាស័ក្តិ និងឯកសណ្ឋាន
មន្ត្រីនៃ ក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ និង ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម

# សញ្ញាស័ក្តិមន្ត្រីសុខាភិបាលមធ្យម (ពណ៌ទឹកប្រាក់)



ស័ក្តិកអាវ



ស័ក្តិប៉ាន់ស្មា



ស័ក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ៩ នៃព្រះរាជក្រឹត្យលេខ នស/រកត/១១០៣/៣៣៤
ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីរូបសញ្ញាសុខាភិបាល សញ្ញាស័ក្តិ និងឯកសណ្ឋាន
មន្ត្រីនៃ ក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ និង ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម

# ក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់



ឯកសណ្ឋានផ្លូវការ

ឧបសម្ព័ន្ធទី ១០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១១០៣/៣៣៤
ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីរូបសញ្ញាសុខាភិបាល សញ្ញាស័ក្តិ និងឯកសណ្ឋាន
មន្ត្រីនៃ ក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ និង ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម

# ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម



ឯកសណ្ឋានផ្លូវការ

ឧបសម្ព័ន្ធទី ១១ នៃព្រះរាជក្រឹត្យលេខ នស/រកត/១១០៣/៣៧២
ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីរូបសញ្ញាសុខាភិបាល សញ្ញាស័ក្តិ និងឯកសណ្ឋាន
មន្ត្រីនៃ ក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ និង ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម

# ក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់



ឯកសណ្ឋានប្រពៃណីជាតិ

ឧបសម្ព័ន្ធទី ១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/១១០៣/៣៣២
ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្ដីពីរូបសញ្ញាសុខាភិបាល សញ្ញាស័ក្តិ និងឯកសណ្ឋាន
មន្ត្រីនៃ ក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ និង ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម

# ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម



ឯកសណ្ឋានប្រពៃណីជាតិ